I ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៣៨ អនក្រ
ស្តីពីការនិយ័តភាពជំពូកចំណាយ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ រាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ដោយ ព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ១៩៩៤ ។

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: អនុញ្ញាតនិយ័តភាព ពីជំពូក ៥០ " ឥណទានសាងសង់ "ទៅជំពូក ៥១ " ឥណទានទទួលសំភារៈ " ជូនទៅរដ្ឋលេខាធិការដ្ឋាន ដូចខាងក្រោម :

- រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ចំនួន : ១៦០.០០០.០០០៛
- រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា : ២០.០០០.០០០៛

មាត្រា២: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលអនុវត្តន៍អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៣៩ អនក្រ

ស្តីពី

ការលុបចោល អនុក្រឹត្យលេខ ១១ អ.ន.ក្រ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពី ការបង្កើតគណៈកម្មការចំរុះ បង្ការបង្ក្រាប សកម្មភាព លួច ឆក់ ប្លន់ ប្រដាប់អាវុធ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ចំនួន ១៦០.០០០.០០០៛
- រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា : ២០.០០០.០០០៛

មាត្រា២: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលអនុវត្តន៍អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៣៩ អនក្រ

ស្តីពី

ការលុបចោល អនុក្រឹត្យលេខ ១១ អ.ន.ក្រ

ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពី

ការបង្កើតគណៈកម្មការចំរុះ បង្ការបង្ក្រាប

សកម្មភាព លួច ឆក់ ប្លន់ ប្រដាប់អាវុធ

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវទុកជានិរាករណ៍ អនុក្រឹត្យ លេខ ១១ អ.ន.ក្រ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពី ការបង្កើត គណៈកម្មការចំរុះបង្ការបង្ក្រាបសកម្មភាព លួច ឆក់ ប្លន់ ប្រដាប់ អាវុធ ។

មាត្រា ២ : នគរបាលជាតិ កងយោធពលខេមរភូមិន្ទ និង កងរាជអាវុធហត្ថជាតិ ត្រូវទទួលបន្ទុកសហការ បង្ការបង្ក្រាបសកម្មភាព លួច ឆក់ ប្លន់ ប្រដាប់អាវុធ តាមភារកិច្ច និង សិទ្ធិ រៀងៗខ្លួន ដែលរាជរដ្ឋាភិបាល បានប្រគល់អោយ។

មាត្រា ៣ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារប្រទេស អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អភិបាលគ្រប់ ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៤០ អនក្រ

ស្តីពីនិយត្តភាពឥណទានរបស់

ក្រសួងមហាផ្ទៃ ពីជំពូក ១១ មកជំពូក ១០

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ រាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ដោយ ព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣។

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ១៩៩៤ ។

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : អនុញ្ញាតអោយធ្វើនិយត្តភាពឥណទានផ្ទៃក្នុងក្រសួងមហាផ្ទៃ «ផ្នែកសន្តិសុខ» ជំពូក ១១ ចំណាយលើឯកសណ្ឋានបញ្ចូលទៅក្នុងជំពូក ១០ «បំប៉នប្រយុទ្ធ» ចំនួន ៣.១៥០.០០០.០០០រ០០ «បីពាន់មួយរយហាសិបលានរៀលគត់»។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៧៧ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោក គួច គី ជាទីប្រឹក្សា ឯកឧត្តម វេង សិរីវុឌ្ឍ រដ្ឋមន្ត្រី ទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ។